ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨០ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ៥៩/អនក្រ/បក ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៩/អនក្រ/បក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណង គ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុដោយធ្វើការផ្លាស់ប្តូរស្ថានភាពពីមន្ត្រីរាជការទៅជានិវត្តជន ជាពិសេសការផ្លាស់ប្តូរពីការទទួលបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ទៅជាការទទួលប្រាក់សោធននិវត្តន៍ជំនួសវិញឱ្យបានទាន់ពេលវេលាដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ។

**មាត្រា ២.-**

អនុក្រឹត្យមិនអនុវត្តចំពោះការដាក់ឱ្យចូលនិវត្តន៍តាមការស្នើសុំ ការចូលនិវត្តន៍ដោយបញ្ញត្តិ និងការចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈទេ។

## ជំពូកទី ២
## ដំណើរការនៃការដាក់ឱ្យចូលនិវត្តន៍តាមអាយុ

**មាត្រា ៣.-**

មន្ត្រីរាជការស៊ីវិលទាំងពីរភេទ ត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតតាមអាយុ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិលទាំងនោះ។

**មាត្រា ៤.-**

ជារៀងរាល់ឆ្នាំ គម្រោងផែនការស្ថិតិ និងថវិកា សម្រាប់មន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍តាមអាយុត្រូវរៀបចំដោយប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបម្រុងថវិកាសម្រាប់ឆ្នាំបន្ទាប់។ ចំពោះគម្រោងស្ថិតិ និងថវិកាសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដោយការស្នើសុំ ដោយបញ្ញត្តិ និងដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈ ជាភារកិច្ចរបស់សាមីក្រសួង ស្ថាប័ននីមួយៗ។

**មាត្រា ៥.-**

បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍នៅគ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវបានបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានយ៉ាងតិច ១២ខែ មុនអាយុចូលនិវត្តន៍។ បញ្ជីនេះត្រូវចម្លងជូនសាមីក្រសួង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៦.-**

ក្រសួង ស្ថាប័នសាមីទាំងអស់ ត្រូវត្រៀមរៀបចំដាក់មន្ត្រីរាជការស៊ីវិលក្នុងបញ្ជីឱ្យចូលនិវត្តន៍ស្របតាមនីតិវិធីជាធរមាន ទៅតាមប្រភេទក្របខណ្ឌរបស់សាមីខ្លួននីមួយៗឱ្យបានមុន ៦ ខែនៃអាយុដែលត្រូវចូលនិវត្តន៍។ ព្រះរាជ-

ក្រឹត្យ អនុក្រឹត្យ ឬប្រកាសស្ដីពីការដាក់ឱ្យចូលនិវត្តន៍ត្រូវចម្លងជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារ-សាធារណៈ។

**មាត្រា ៧.–**

ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវធ្វើការរំលឹកមួយដងដល់ក្រសួង ស្ថាប័នសាមី ហើយបើនៅតែមានការយឺតយ៉ាវទៀតនោះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវកាត់ឈ្មោះចេញពីតារាងទូទាត់ប្រាក់បៀវត្សជាស្វ័យប្រវត្តិ ហើយសាមីក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវទាំងស្រុងអំពីបែបបទនៃការដាក់មន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យចូលនិវត្តន៍។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៨.–**

ចំពោះមន្ត្រីរាជកាស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ការដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើដោយដៃ។

**មាត្រា ៩.–**

ចំពោះបញ្ជីរាយនាមមន្ត្រីរាជកាស៊ីវិលទាំងអស់ដែលមានអាយុចូលនិវត្តន៍នៅឆ្នាំ ២០០៣ ត្រូវបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានមុនដំណាច់ខែ សីហា ឆ្នាំ២០០២។

**មាត្រា ១០.–**

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ការរៀបចំដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើឱ្យបានមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១១.–**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ-កាលប្បវត្តិ